សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ
LICADHO
CAMBODIAN LEAGUE FOR THE PROMOTION AND DEFENSE OF HUMAN RIGHTS
ផ្ទះលេខ ១៦ ផ្លូវលេខ ៩៩ ប្រអប់សំបុត្រ ៤៩៩ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ: (+៨៥៥) ២៣ ៧២៧ ១០២/២១៦ ៦០២ ទូរសារ: (+៨៥៥) ២៣ ៧២៧ ១០២/២១៧ ៦២៦ អ៊ីមែល: contact@licadho-cambodia.org

# របាយការណ៍សង្ខេបបច្ចុប្បន្នភាព: ករណីរបស់អ្នកស្រី យ៉ោម បុប្ផា

ថ្ងៃទី ២៧ ខែមីនាឆ្នាំ ២០១៣៖ ថ្មីៗនេះមានការមិនច្បាស់លាស់ខ្លះជុំវិញករណីព្រហ្មទណ្ឌប្រឆាំងនឹងអ្នកស្រី យ៉ោម បុប្ផា ដែលជាសកម្មជនសហគមន៍បឹងកក់។ ភាពមិនច្បាស់លាស់នៃអង្គហេតុនានា ដែលបណ្តាលឲ្យមានការយល់ច្រឡំនេះ មិនមែនជារឿងចៃដន្យទេ (វាឆ្លុះបញ្ចាំងនូវយុទ្ធនាការឃោសនាដោយចេតនាមួយពីអាជ្ញាធរ ជាមួយនឹងការចោទដោយគ្មានភស្តុតាងដែលអាចជឿបានថា អាជ្ញាធរបានផ្តល់ប្រាក់ទៅឲ្យអ្នកតវ៉ាប្រឆាំងតបវិញ ព្រមទាំងការពាក់ព័ន្ធថ្មីៗនេះពីសម្តេចនាយករដ្ឋមន្ត្រីដោយផ្ទាល់ ដែលគួរឲ្យព្រួយបារម្ភ។ ធាតុពិតអង្គហេតុទាំងឡាយ ដែលគូសបញ្ជាក់ពីការកាត់ទោសអ្នកស្រី យ៉ោម បុប្ផា ដោយអយុត្តធម៌ ហើយបង្ហាញឲ្យឃើញដោយគ្មានសង្ស័យថា




អាជ្ញាធរបានកំណត់អ្នកស្រី បុប្ផា ជាគោលដៅដើម្បី បង្កការភ័យខ្លាច និងការពិនិត្យចាប់ពិរុទ្ធក្នុងចំណោមសមាជិកសកម្មសេសសល់របស់ សហគមន៍បឹងកក់ ដែលពោរពេញទៅដោយបញ្ហា។

អង្គហេតុនានានៃព្រឹត្តិការណ៍ដែលមិនគួរសង្ស័យ នាំឲ្យមានការចោទប្រកាន់មានដូចតទៅ: បុរសចំនួន ២ នាក់កំពុងតែទទួលទានស្រាអស់រយៈពេលជាច្រើនម៉ោង នៅឯតៀមស្រាមួយក្នុងសហគមន៍បឹងកក់។ ក្រោយពេលងងឹតបន្តិចជម្លោះមួយបានកើតឡើង នៅពេលនោះបុរស ២ នាក់បានទទួលរងរបួស។ អ្នកស្រី បុប្ផា និងស្វាមីរបស់អ្នកស្រី បានមកដល់តៀមស្រានោះ ក្រោយពីជម្លោះបានកើតឡើង ហើយអ្នកទាំង ២ ព្រមទាំងអ្នកឃើញហេតុការណ៍ផ្សេងទៀត បានមើលឃើញហេតុការណ៍នេះពីខាងក្រៅតៀមស្រា។ បុរសម្នាក់ក្នុងចំណោម ២ នាក់នោះ កាលពីពេលមុនធ្លាប់ត្រូវបានគេចោទប្រកាន់ជាច្រើនដងថាបានលួចកញ្ចក់រថយន្តរបស់អ្នកភូមិនៅក្នុងតំបន់នោះ ហើយអ្នកស្រី បុប្ផា ក៏ធ្លាប់បានរាយការណ៍ជូនមន្ត្រីនគរបាលថា កញ្ចក់រថយន្តរបស់អ្នកស្រីក៏ត្រូវបានចោរលួចច្រើនដងផងដែរ។ ក៏ប៉ុន្តែអ្នកស្រី មិនដែល

**គេហទំព័រ:** licadho-cambodia.org • facebook.com/licadho • twitter.com/licadho
**ការិយាល័យខេត្ត:** បាត់ដំបង: (០៥៣) ៩៥២ ៨២៨ • បន្ទាយមានជ័យ: (០៥៤) ៩៥៨ ៨៦១ • កោះកុង: (០៣៥) ៩៣៦ ១១៦ • កំពង់ចាម: (០៤២) ៩៤១ ៤៦៤
កំពង់ឆ្នាំង: (០២៦) ៩៨៨ ៦៣៧ • កំពង់ស្ពឺ: (០២៥) ៩៨៧ ២២០ • កំពង់ធំ: (០៦២) ៩៦១ ២៩២ • កំពត: (០៣៣) ៩៣២ ៦៦៣ • ពោធិ៍សាត់: (០៥២) ៩៥១ ៤៩៦
សៀមរាប: (០៦៣) ៩៦៤ ០៦៦ • ព្រះសីហនុ: (០៣៤) ៩៣៣ ៧១៦ • ស្វាយរៀង: (០៤៤) ៩៤៥ ៨៣៣

ចោទប្រកាន់អ្នកណាម្នាក់ពីការលួចនេះទេ។ ការចោទប្រកាន់ដោយគ្មានភស្តុតាងមួយទៀតនេះ ក៏មិនត្រឹមត្រូវផងដែរ។

សារតារអំពីអ្នកស្រី យ៉ោម បុប្ផា ក៏មិនធ្លាប់មានអ្នកជំទាស់ផងដែរ។ នៅអំឡុងខែឧសភាកន្លងទៅ សមាជិកជាស្ត្រីរបស់សហគមន៍បឹងកក់ចំនួន ១៣ នាក់ត្រូវបានគេព័ទ្ធចាប់ខ្លួននៅពេលកំពុងធ្វើការតវ៉ាដោយសន្តិវិធីមួយ នៅកន្លែងបូមខ្សាច់ចាក់បំពេញ ដែលជាអតីតទីកន្លែងផ្ទះសម្បែងរបស់អ្នកទាំងនោះ។ អ្នកស្រី បុប្ផា សុខចិត្តប្រកាន់យកកិច្ចខិតខំប្រឹងប្រែងតស៊ូមតិក្នុងនាមសហគមន៍ ខណៈដែលស្ត្រីចំនួន ១៣ នាក់ត្រូវបានឃុំខ្លួនក្នុងពន្ធនាគារ។ ភាពក្លាហាននេះមិនមែនអាថ្កាធរ មិនបានធ្វើការកត់សំគាល់នោះទេ។ ភ្លាមនោះលោកស្រីបានទទួលរងនូវការគំរាមកំហែង ការរំខានរុកគួន និងការបំភិតបំភ័យ។ មន្ត្រីនគរបាលបានប្រាប់អ្នកស្រីដោយចំហថា អ្នកស្រីមានឈ្មោះ "ក្នុងបញ្ជីខ្មៅ" ហើយថាអ្នកស្រីនឹងមាន "បញ្ហាឆាប់ៗខាងមុខនេះ"។

ឱកាសនោះបានមកដល់នៅពេលអ្នកស្រី និងស្វាមីរបស់អ្នកស្រី លោក លួស សាខម កំពុងនិយាយជាមួយអ្នកជិតខាងម្នាក់នៅពេលល្ងាចមួយ ខណៈដែលជម្លោះវាយតប់គ្នាបានកើតឡើងនៅក្បែរនោះ។ បងប្អូនប្រុស ២ នាក់របស់អ្នកស្រី បុប្ផា ឈ្មោះ យ៉ោម កាំហុង និង យ៉ោម សិដ្ឋ ក៏ត្រូវទទួលរងនូវការចោទប្រកាន់ថា បានចូលរួម និងបានញុះញង់ឲ្យមានជម្លោះនោះកើតឡើង។ ប៉ុន្តែអ្នកស្រី យ៉ោម បុប្ផា និងស្វាមីរបស់អ្នកស្រីមិនបានធ្វើអ្វីទាល់តែសោះក្រៅតែពីដើរទៅកាន់ទីកន្លែងកើតហេតុ ដើម្បីទៅមើលមានអ្វីកើតឡើង ដូចដែលអ្នកមានវត្តមានទាំងអស់នៅអំឡុងពេលសវនាការរបស់អ្នកស្រី បានដឹងយ៉ាងច្បាស់។

សវនាការត្រូវបានធ្វើឡើងអស់រយៈពេលជិត ៥ ម៉ោងដោយគ្មានវត្តមានបងប្អូនប្រុសរបស់អ្នកស្រី បុប្ផា កាលពីថ្ងៃទី ២៦ ខែធ្នូ។ ទ្រឹស្តីនៃចោទប្រកាន់ទំនងជាថាអ្នកស្រី បុប្ផា និងស្វាមីអ្នកស្រីគឺជាមេគំនិតក្នុងការវាយប្រហារទៅលើបុរសទាំង ២ នាក់នោះដែលកំពុងអង្គុយក្នុងតៀមស្រា ហើយបន្ទាប់មកបានចូលមកពិនិត្យមើលអំពីផែនការសកម្មភាពរបស់ពួកគេ។



គ្មានសាក្សីណាម្នាក់មានវត្តមានក្នុងតុលាការ ដើម្បីឆ្លើយបំភ្លឺទ្រឹស្តីទាក់ទងនឹងផែនការ ដែលត្រូវបានរៀបចំទុកជាមុន ដែលនេះទំនងពឹងផ្អែកទាំងស្រុងទៅលើអង្គហេតុ ដែលថា ជនជាប់ចោទ ២ នាក់ទៀត ដែលគ្មានវត្តមាន ជាសាច់ញាតិនឹងអ្នកស្រី បុប្ផា។ ផ្ទុយទៅវិញបុរស ២ នាក់ ដែលរងរបួសក្នុងជម្លោះនោះ បានឆ្លើយបំភ្លឺអំពីព្រឹត្តិការណ៍នៅល្ងាចថ្ងៃកើតហេតុនោះ ហើយនិងមនុស្ស ២ នាក់ផ្សេងទៀត (ម្នាក់ជាឪពុករបស់បុរសម្នាក់ដែលរងរបួស និងម្នាក់ទៀតដែលត្រូវគេសន្មតថាជាអ្នកឃើញហេតុការណ៍) បានឆ្លើយបំភ្លឺពីអ្វីដែលអ្នកទាំងនោះបានឃើញ នៅពេលអ្នកទាំងនោះមកដល់កន្លែងកើតហេតុ ក្រោយពេលជម្លោះបានកើតឡើង។ ជាថ្មីម្តងទៀតគ្មានជន ណាម្នាក់បានឆ្លើយបំភ្លឺអំពីអង្គហេតុណាមួយ ដែលបង្ហាញថាជនត្រូវចោទបានរៀបចំផែនការវាយប្រហារទៅលើបុរសទាំងនេះមុនថ្ងៃកើតហេតុឡើយ។ សូម្បីតែព្រះរាជអាជ្ញាក៏គ្មានបំណង ធ្វើការបញ្ជាក់បង្ហាញចំណុចនេះផងដែរ ប្រហែលលើកលែងតែការពិភាក្សាដេញដោលដដែលៗច្រើនដង ហើយនឹងមិនពាក់ព័ន្ធទៅនឹងពេលណាដែលអ្នកស្រី យ៉ម បុប្ផា និងស្វាមីរបស់អ្នកស្រី បានឃើញបងប្អូនប្រុសរបស់អ្នកស្រី ជាចុងក្រោយ។

ម្យ៉ាងវិញទៀតមានភាពមិនស៊ីសង្វាក់គ្នាយ៉ាងច្រើនក្នុងសក្ខីកម្មរបស់សាក្សីដាក់បន្ទុក (ជាពិសេសរវាងសក្ខីកម្មក្នុងបន្ទប់សវនាការ និងចម្លើយជាលាយល័ក្ខណ៍អក្សររបស់ពួកគេនៅក្នុងសំណុំរឿង)។ លើសពីនេះទៅទៀត មានសណ្ឋានដូចគ្នាគួរឲ្យកត់សំគាល់ក្នុងសក្ខីកម្មរបស់សាក្សីក្នុងតុលាការ។ ឧទាហរណ៍: ពួកគេសុទ្ធតែបានលើកពីចំណុចដែលឆ្លើយថា អាវុធប្រើសំរាប់វាយប្រហារ (ទូលវិស) មានដងពណ៌ខៀវ (សូម្បីតែកន្លែងខ្លះលើកពីចំណុចនេះមិនស្របគ្នាគួរឲ្យចម្លែក ហើយមិនស្របគ្នាទៅនឹងសំនួរឡើយ)។ រាល់សាក្សីបានឆ្លើយបំភ្លឺដោយទុកចិត្តលើខ្លួនឯង និងដ៏ដែលៗផងដែរថាជម្លោះនេះ បានចាប់ផ្តើមកើតឡើងនៅម៉ោង ៧:១០ នាទីយប់ ទោះជាដើមបណ្តឹងរដ្ឋប្បវេណី ២ នាក់នោះទទួលស្គាល់ថាបានទទួលទានស្រា អស់

រយៈពេលជាច្រើនម៉ោង ហើយមនុស្ស ២ នាក់ផ្សេងទៀតអះអាងថាទើបតែបានមកដល់កន្លែងកើតហេតុក្រោយពេលជម្លោះ បានចាប់ផ្ដើមកើតឡើងរួចហើយក៏ដោយ។

សំខាន់ជាងនេះទៅទៀតនោះរាល់សាក្សីបានឆ្លើយថាអ្នកស្រី បុប្ផា និងស្វាមីលោកស្រីមិនបានប្រព្រឹត្តអំពើហិង្សាដោយផ្ទាល់ទេ ហើយថាអ្នកស្រី និងស្វាមីអ្នកស្រី ទើបតែមានវត្តមានក្រោយពេលជម្លោះបានកើតឡើងរួចហើយ ហើយនិងមានវត្តមាននៅខាងក្រៅតៀមស្រាតែប៉ុណ្ណោះ។ អ្នកស្រី បុប្ផា និងស្វាមីអ្នកស្រីបានឆ្លើយបំភ្លឺថា អ្នកទាំងពីរមានវត្តមាននៅជិតនោះដោយកំពុងនិយាយជាមួយអ្នកជិតខាងម្នាក់ ហើយក៏បានដើរទៅកាន់តៀមស្រាក្រោយពីឮសម្លេងស្រែក។ អ្នកជិតខាងនោះបានឆ្លើយស៊ីសង្វាក់ជាមួយសក្ខីកម្មនេះ។

ភាពខុសគ្នាខាងនីតិវិធីជាច្រើន មានសារៈសំខាន់គ្រប់គ្រាន់ ដែលត្រូវលើកឡើងផងដែរ។ ដូចបានកត់សំគាល់ខាងលើ សាក្សី ២ នាក់ដំបូងដែលឆ្លើយដាក់បន្ទុកទៅលើអ្នកស្រីបុប្ផា និងស្វាមីរបស់អ្នកស្រី គឺត្រូវបានបញ្ជាក់ដោយគ្មានភស្តុតាងថាជាជនរងគ្រោះដោយផ្ទាល់។ ជនរងគ្រោះទាំង ២ នាក់នេះ ក៏ជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងករណីនេះ ហើយជាអ្នកទាមទារ សំណងយ៉ាងក្រាស់ក្រែលផងដែរ។ ដូច្នេះ ក្រមនីតិវិធីព្រហ្មទណ្ឌអនុញ្ញាតឲ្យជនរងគ្រោះស្ថិតនៅក្នុងបន្ទប់សវនាការរហូតដល់ចប់សវនាការ។ ជាធម្មតាសាក្សីក្នុងរឿងព្រហ្មទណ្ឌ តម្រូវឲ្យស្ថិតនៅខាងក្រៅបន្ទប់សវនាការ នៅពេលសាក្សីផ្សេងទៀតកំពុងចូលឆ្លើយបំភ្លឺដើម្បីកុំឲ្យពួកគេផ្លាស់ប្ដូរសក្ខីកម្មដើម្បីឲ្យស៊ីសង្វាក់ជាមួយសាក្សីដ៏ទៃៗទៀត។ វាមានលក្ខណៈមិនច្បាស់លាស់អំពីសិទ្ធិទាំងនេះ អាចត្រូវដោះស្រាយរបៀបណា ដើម្បីរក្សាបាននូវភាពត្រឹមត្រូវខាងនីតិវិធីព្រហ្មទណ្ឌ។ វាមានលក្ខណៈមិនច្បាស់លាស់អំពីបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលហាមឃាត់ដើមបណ្ដឹងរដ្ឋប្បវេណី មិនឲ្យផ្ដល់សក្ខីកម្មក្នុងឋានៈជាសាក្សី អាចត្រូវអនុវត្តស្ថានភាពបែបនេះ។ (សូមមើលមាត្រា ៣១២: "ដើមបណ្ដឹងរដ្ឋប្បវេណីមិនអាចត្រូវគេស្ដាប់យកចម្លើយក្នុងឋានៈជាសាក្សីបានទេ")។ ប្រសិនបើដើមបណ្ដឹងរដ្ឋប្បវេណីផ្ដល់សក្ខីកម្ម ប៉ុន្ដែមិនបានធ្វើសម្បថ តាមទឡ្ហីករណ៍សក្ខីកម្មនោះ មិនមានលក្ខណៈគ្រប់គ្រាន់ជាភ័ស្តុតាងគួរឲ្យជឿជាក់បានឡើយ។




និយាយតាមការជាក់ស្ដែងវិញ ក្នុងករណីរបស់អ្នកស្រីបុប្ផា ប្រការនេះមានន័យថា ជនរងគ្រោះទាំង ២ នាក់នេះ អាចស្ដាប់ឮសក្ខីកម្មពីគ្នាទៅវិញទៅមកយ៉ាងប្រុងប្រយ័ត្ន មុនពេលអ្នកទាំងពីរឆ្លើយរៀបរាប់ពីព្រឹត្តិការណ៍នានាដោយផ្ទាល់។ ដូច្នេះវាមិនចំឡែកទេដែលថាអង្គហេតុជាក់លាក់នានា ត្រូវបានគេរៀបរាប់ដដែលៗច្រើនដង ទោះជាការរៀបរាប់ដដែលៗនោះគ្មានន័យក៏ដោយ។ មើលឃើញជាក់ស្ដែងផងដែរនូវភាពមិនសមស្របក្នុងការអនុញ្ញាតឲ្យបុរសទាំងនេះ ស្ថិតនៅក្នុងបន្ទប់សវនាការ ហើយនឹងអាចស្ដាប់ចម្លើយគ្នាទៅវិញទៅមក នៅពេលបុរសម្នាក់ត្រូវបានសាកសួរនូវសំណួរ ដែលសំណួរនេះមិនត្រូវបានតាំងសំរាប់បុរស់ម្នាក់ទៀត។ បុរសម្នាក់ដែលកំពុងឆ្លើយបំភ្លឺ បានងាកក្រោយមើលសហដើមបណ្ដឹងរដ្ឋប្បវេណីរបស់ខ្លួនភ្លាមៗ ទំនងជាសួរម្នាក់ទៀតថា "តើពួកយើងត្រូវនិយាយយ៉ាងដូចម្ដេចចំពោះចំណុចនេះ?"។

ត្រូវកត់សំគាល់ផងដែរថាអ្នកស្រីបុប្ផា និងស្វាមីរបស់អ្នកស្រី មិនត្រូវទទួលរងនូវការចោទប្រកាន់តាមបទប្បញ្ញត្តិព្រហ្មទណ្ឌណាមួយ ដែលតម្រូវឲ្យមានការទទួលខុសត្រូវជំនួសឡើយ។ ម្យ៉ាងវិញទៀតអ្នកទាំងពីរក៏មិនបានទទួលរងនូវការចោទប្រកាន់ជាអ្នកសមគំនិត ឬជាអ្នកផ្ដើមគំនិតឡើយ ប៉ុន្តែបែរចោទពីបទជាចារីនៃអំពើហិង្សាដោយផ្ទាល់ទៅវិញ។ សក្ខីកម្មក្នុងតុលាការ និងការលើកសំអាងរបស់តំណាងព្រះរាជអាជ្ញា បានបង្ហាញឲ្យឃើញថាជនជាប់ចោទទាំង ២ នាក់នេះ មិនអាចត្រូវបានរកឃើញពីរុទ្ធភាពក្នុងការប្រព្រឹត្តបទល្មើសនោះទេ (គ្មានជនណាម្នាក់ត្រូវ បានចោទប្រកាន់ពីបទវាយប្រហារជាក់ស្ដែងទៅលើបុគ្គលណាមួយឡើយ)។ ហើយទោះជាស្ថិតក្នុងព្រឹត្តិការណាក៏ដោយ ទ្រឹស្ដីនៃការទទួលខុសត្រូវជំនួសត្រូវការភស្តុតាងច្រើនថែមទៀត ជាជាងគ្រាន់តែបង្ហាញថាមនុស្សផ្សេងទៀត ដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ គឺជាញាតិលោហិត។

ទោះជាមានភាពមិនស៊ីសង្វាក់គ្នាទាំងនេះ និងមានភាពមិនស៊ីសង្វាក់គ្នាផ្សេងៗទៀតយ៉ាងច្រើនលើសលុបក៏ដោយ ក៏ជនត្រូវចោទទាំង ៤ នាក់ត្រូវបានផ្ដន្ទាទោសនៅថ្ងៃទី ២៧ ខែធ្នូឆ្នាំ២០១២ ពីបទហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសតាមមាត្រា ២១៨ នៃក្រមព្រហ្ម

ទណ្ឌ និងកាត់ទោសឲ្យជាប់ពន្ធនាគារចំនួន ៣ ឆ្នាំ។ តុលាការបង្គាប់ឲ្យជនជាប់ចោទទាំង ៤ នាក់បង់សំណង ៣០ លានរៀល (ប្រហែល ៧,៥០០ ដុល្លាអាមេរិក) ទៅឲ្យជនរងគ្រោះទាំង ២ នាក់ផងដែរ។ ជាគំរូយ៉ាងជាក់ស្ដែងមួយទៀតដែលថា ករណីនេះត្រូវបានគេរៀបចំឡើងទាំងស្រុងដើម្បីកំណត់អ្នកស្រី បុប្ផា ជាគោលដៅនោះ គឺទោសស្វាមីរបស់អ្នកស្រីត្រូវ បានព្យួរ ហើយក៏ត្រូវបានដោះលែងភ្លាមៗបន្ទាប់ពីសវនាការ។

អ្នកស្រី បុប្ផា ដែលត្រូវបានអង្គការលើកលែងទោសអន្តរជាតិ កំណត់ថាជាអ្នកទោសមនសិការ ត្រូវបានឃុំខ្លួនក្នុងពន្ធនាគារចាប់ពីថ្ងៃទី ៤ ខែកញ្ញា ឆ្នាំ២០១២។ បណ្ដឹងឧទ្ធរណ៍របស់អ្នកស្រី មិនទាន់ត្រូវបានកំណត់ថ្ងៃបើកសវនាការទេ ហើយតុលាការកំពូលបានបដិសេធសំណើអ្នកស្រីសុំនៅក្រៅឃុំ ដើម្បីរង់ចាំសវនាការលើបណ្ដឹងឧទ្ធរណ៍។

យើងខ្ញុំស្នើសុំយ៉ាងទទូចដល់សាលាឧទ្ធរណ៍ សូមលោកមេត្តាពិនិត្យទឡ្ហីករណ៍ទាំងឡាយ ដែលបានបង្ហាញជូនខាងលើ ព្រមទាំងការកង្វះភស្ដុតាងទាំងស្រុងដែលគួរឲ្យជឿជាក់បាន ហើយនឹងបដិសេធចោលនូវសាលក្រមសាលាដំបូង។